NSW GOVERNMENT Education Public Schools

Drive and park safely near schools

ព័ត៌មានអំពីសុវត្ថិភាពតាមដងផ្លូវ

លោកអ្នកទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់កូនលោកអ្នក នៅពេលកូនលោកអ្នកធ្វើដំណើរទៅកាន់និងវិលត្រឡប់ពីសាលារៀន។

បើកបរនិងចតដោយសុវត្ថិភាពនៅក្បែរសាលារៀន

ពេលចាប់ផ្តើមនិងពេលបញ្ចប់ថ្ងៃសិក្សានីមួយៗ គឺជាពេលមមាញឹកសម្រាប់អ្នកថ្មើរជើងនិងអ្នកបើកបរយានយន្ត នៅក្រៅសាលារៀន។

លោកអ្នកអាចជួយរក្សាសុវត្ថិភាពរបស់កូនលោកអ្នក តាមរយៈការចងចាំចំណុចដូចតទៅ៖

- ដាក់កូននិងទៅយកកូននៅចំហៀងផ្លូវខាងសាលារៀន
- កុំហៅកូនពីចំហៀងផ្លូវម្ខាងទៀតឱ្យ សោះ – ទង្វើនេះមានគ្រោះថ្នាក់ណាស់
- យកចិត្តទុកដាក់បន្ថែមជានិច្ច នៅពេលបើកបរក្នុងតំបន់សាលារៀនតាមល្បឿនកំណត់មិនឲ្យលើសពី 40គីឡូម៉ែត្រ
- ធ្វើតាមសញ្ញាចំណតទាំងអស់ – សញ្ញាទាំងនេះរក្សាកុមារឱ្យមានសុវត្ថិភាពទៅតាមលទ្ធភាព
- ចតដោយមានការទទួលខុសត្រូវ ទោះជាការចតដូចនេះមានន័យថាលោកអ្នកត្រូវដើរថែមទៀតទៅកាន់ទ្វាររបងសាលារៀនក៏ដោយ
- កុំចតទន្ទឹមគ្នាឱ្យសោះ – វាជាអំពើខុសច្បាប់ និងធ្វើឱ្យកុមារអាចមានគ្រោះថ្នាក់
- កុំបត់បកក្រោយទម្រង់ U-turn ឬទម្រង់ three-point turn នៅខាងក្រៅសាលារៀនឡើយ ដោយសារតែវាអាចធ្វើឱ្យកុមារមានគ្រោះថ្នាក់
- ធ្វើគំរូឱ្យកូនលោកអ្នករៀនសូត្រធ្វើតាមឥរិយាបថមានសុវត្ថិភាពនិងមានការយកចិត្តទុកដាក់ចំពោះអ្នកថ្មើរជើងនិងអ្នកបើកបរ។

ដើម្បីទទួលជំនួយបន្ថែម

សូមអានកម្មវិធីអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវរបស់ក្រសួង នៅឯ https://education.nsw.gov.au/road-safety-education ឬបើកមើល https://education.nsw.gov.au ហើយស្វែងរកមើលការអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវ។

នៅពេលធ្វើដំណើរក្នុងរថយន្ត ត្រូវធ្វើឱ្យច្បាស់ថាកូនលោកអ្នក៖

- ប្រើកៅអីកំណល់បន្ថែម បើកូនលោកអ្នកមានអាយុចន្លោះពី 4 ទៅ 7ឆ្នាំ – នេះជាតម្រូវការរបស់ច្បាប់
- បំពាក់ខ្សែក្រវាត់រថយន្តឱ្យកូនឱ្យបានត្រឹមត្រូវ
- ចេញចូលរថយន្តតាមរយៈ 'ទ្វារសុវត្ថិភាព'ជានិច្ច – ទ្វារក្រោយនៅខាងផ្លូវដើរនៃរថយន្ត
- កុំទុកកូនចោលនៅក្នុងរថយន្តតែម្នាក់ឯងឱ្យសោះ។

រហូតដល់ 6 ខែ
កៅអីកូនក្មេងសម្រាប់ប្រើក្នុងរថយន្តដែលបែរមុខទៅទិសខាងក្រោយ និងដែលអនុញ្ញាតដោយច្បាប់

6 ខែ ដល់ 4 ឆ្នាំ
កៅអីកូនក្មេងសម្រាប់ប្រើក្នុងរថយន្តដែលបែរមុខទៅទិសខាងក្រោយ ឬមើលទៅខាងមុខ ដែលអនុញ្ញាតដោយច្បាប់

4 ឆ្នាំឡើងទៅ
កៅអីកូនក្មេងសម្រាប់ប្រើក្នុងរថយន្តដែលមើលទៅទិសខាងមុខ ឬកៅអីកំណល់បន្ថែមដែលអនុញ្ញាតដោយច្បាប់

145សង់ទីម៉ែត្រ ឬខ្ពស់ជាងនេះ
សំណើកម្ពស់យ៉ាងតិចដើម្បីប្រើខ្សែក្រវាត់រថយន្តដែលពាក់ផ្ទៀងលើស្មានិងលើភ្លៅសម្រាប់ជនពេញវ័យ